## សន្លឹកព័ត៌មានទី១: ការបង់ប្រាក់របស់មាតាបិតានៅតាមសាលារៀនរដ្ឋ
## INFO SHEET 1: PARENT PAYMENTS IN STATE SCHOOLS (Cambodian)

តើលោកអ្នកមានបញ្ហាក្នុងការបង់ថ្លៃសាលារៀនឬ? **សន្លឹកព័ត៌មាននេះពន្យល់ប្រាប់លោកអ្នកអំពីអ្វីខ្លះដែលលោកអ្នក និងសាលារៀនអាចរំពឹងទុក និងអ្វីដែលត្រូវធ្វើអំពីបញ្ហាបង់ថ្លៃសាលារៀន។**

## អ្វីដែលលោកអ្នកអាចធ្វើ

### សាងសង់នូវទំនាក់ទំនងល្អជាមួយសាលារៀន – ការនេះមានសារៈសំខាន់ដល់ការអប់រំរបស់កូនលោកអ្នក។

សាលារៀនពុំចង់ឲ្យមានសិស្ស*ណាម្នាក់*ខកខានមិនបានមករៀនឡើយ។

- និយាយទៅកាន់អ្នកសំរបសំរួលសុខុមាលភាពសិស្ស ឬនាយកសាលា។
- សាលារៀនអាចជួយបាន ដោយរៀបចំឲ្យមានគំរោងបង់ថ្លៃសាលារៀន។
- ប្រើតួបលក់សៀវភៅដែលគេប្រើរួចហើយ ឬហាងលក់ឯកសណ្ឋានសាលា ដែលគេពាក់រួចហើយ។
- ប្រសិនបើលោកអ្នកមានជំរើស សូមជ្រើសរើសយកសាលារៀនណាដែលយល់ច្បាស់អំពីសម្ពាធថវិកាដែលមានដល់មាតាបិតា។
- **សូមអានសន្លឹកព័ត៌មានទី៤ ដើម្បីទទួលយកជំនួយបន្ថែមទៀត**

### ស្វែងរកជំនួយថវិកា

- ប្រសិនបើលោកអ្នករស់នៅដោយពឹងផ្អែកលើប្រាក់ចំណូលតិច លោកអ្នកប្រហែលជាមានសិទ្ធិទទួលយកប្រាក់ជំនួយឧបត្ថម្ភលើការសិក្សា (EMA)។ សូមសួរនៅតាមសាលារៀនរបស់លោកអ្នក ឬឆែកមើលនៅតាមវ៉ិបសាយ: www.education.vic.gov.au
- ប្រសិនបើកូនរបស់លោកអ្នកចាប់ផ្តើមចូលបុព្វសាលា ឬថ្នាក់ទី៧ លោកអ្នកប្រហែលជាមានសិទ្ធិទទួលយកប្រាក់លើកទឹកចិត្តការចាប់ផ្តើមចូលរៀន។ សូមសួរនៅតាមសាលារៀនរបស់លោកអ្នក ឬឆែកមើលនៅតាមវ៉ិបសាយ: www.education.vic.gov.au
- ដើម្បីទទួលយកជំនួយផ្នែកឯកសណ្ឋាន និងស្បែកជើងសាលា សូមនិយាយទៅកាន់នាយកសាលាអំពីគណៈកម្មការអនុគ្រោះសាលារៀនរដ្ឋ។
- សូមសួរកិច្ចបំរើផ្តល់ព័ត៌មានសហគមន៍ប្រចាំតំបន់របស់លោកអ្នក អំពីជំនួយឯទៀតដែលមានផ្តល់: ទូរស័ព្ទ 96722000 ឬឆែកមើលនៅតាមវ៉ិបសាយ: www.civ.org.au ឬទាក់ទងជាមួយសាលាសង្កាត់របស់លោកអ្នក។

## ការសិក្សាអប់រំដោយឥតគិតថ្លៃគឺជាច្បាប់

- **ការបង្រៀនអប់រំនៅក្នុងវិស័យរៀនសូត្រសំខាន់ៗទាំងនេះគឺឥតគិតថ្លៃ: ភាសាអង់គ្លេស សិល្បៈ សុខភាព ហាត់ប្រាណ បច្ចេកទេស ភាសាផ្សេងៗ គណិតសាស្ត្រ វិទ្យាសាស្ត្រ ការសិក្សាអំពីសង្គម និងបរិដ្ឋាន។**
- **ការនេះក៏មានរួមបញ្ចូលផងដែរនូវធនធាន ការឧបត្ថម្ភ និងការចាត់ចែងដែលតម្រូវដើម្បីបង្រៀនអំពីស្តង់ដារកម្មវិធីសិក្សា ដូចជាការបង្រៀនផងដែរ ឧទាហរណ៍ បណ្ណាល័យ គិលានុបដ្ឋាកសាលា ប័ណ្ណអត្តសញ្ញាណ ការបោះជុំរំខ្លះៗ កីឡាសាលា ខុមព្យូធើរ ការបោះពុម្ពចម្លង និងការបោះពុម្ពចាំបាច់ឯទៀត។ល។**

**រដ្ឋាភិបាលផ្គត់ផ្គង់ថវិកាសំរាប់មុខវិជ្ជា និងធនធានទាំងនេះ ហើយសាលារៀនមិនត្រូវគិតថ្លៃលើរបស់ទាំងនេះឡើយ។**

## ក៏ប៉ុន្តែមាតាបិតាត្រូវជួយបង់លើថ្លៃសិក្សាអប់រំខ្លះ

**សូមអានទំព័រខាងក្រោយដើម្បីទទួលយកព័ត៌មានពិស្តារ**

### សាលារៀនគួរតែ:

- ផ្ញើការស្នើសុំឲ្យបង់ថ្លៃសាលារៀន យ៉ាងហោចណាស់ឲ្យបាន**៦អាទិត្យ**មុនចុងឆ្នាំសិក្សា
- សំគាល់ឲ្យបានច្បាស់លាស់ថាតើការបង់ថ្លៃនីមួយគឺសំរាប់មុខរបស់**សំខាន់ចាំបាច់ មុខវិជ្ជាតាមការជ្រើសរើស ឬការបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្ត**
- ឲ្យបានច្បាស់ប្រាកដថាមុខរបស់ដែលត្រូវបង់ ត្រូវបាន**គិតថ្លៃត្រឹមត្រូវច្បាស់លាស់**
- ផ្តល់នូវព័ត៌មានអំពីបែបយ៉ាងណាដែលថវិកាប្រមូលបាននឹងត្រូវ**ចំណាយ**ដោយសាលារៀន
- ផ្តល់ដល់មាតាបិតាទាំងអស់នូវច្បាប់ចម្លងនៃ**គោលការណ៍របស់សាលារៀន**ស្តីអំពីការបង់ប្រាក់
- ផ្តល់នូវ**បង្កាន់ដៃ**ឲ្យបានភ្លាមៗចំពោះការបង់ប្រាក់
- ពន្យល់ឲ្យបានច្បាស់លាស់ពីដំណើរនៃការចាត់ចែងប្រាក់ **EMA**
- **រៀបចំពេលបង់ប្រាក់**ឲ្យត្រូវពេលគ្នានឹងថ្ងៃទទួលប្រាក់ EMA
- ឲ្យមានការដឹងយល់ទៅនឹង**កាលៈទេសៈផ្នែកថវិការបស់បុគ្គលម្នាក់ៗ**
- **ផ្តល់នូវជំរើសបង់ប្រាក់** (ឧទាហរណ៍ ៣ខែម្តង)
- ផ្តល់ដល់សិស្សនូវជំរើសផ្សេងទៀត ប្រសិនបើគេមិនចូលរួមនៅក្នុង**ការបោះជុំរំ ឬដំណើរសិក្សាសាលា**
- រក្សាទុកនូវព័ត៌មានអំពីការបង់ប្រាក់ និងការមិនបានបង់ប្រាក់**ដោយសម្ងាត់**
- **ឲ្យបានច្បាស់ប្រាកដថាការស្នើសុំឲ្យបង់ប្រាក់ទាំងអស់គឺសមរម្យ សមហេតុផល ហើយរក្សាឲ្យមានតិចបំផុត។**

### សាលារៀនមិនអាច:

- ចាត់ទុកសិស្សថាខុសៗគ្នា ឬប្រកែកមិនព្រមបង្រៀនដល់គេ ប្រសិនបើមាតាបិតាមិនបានបង់ប្រាក់
- ប្រកែកមិនឲ្យឡើងថ្នាក់នៅឆ្នាំខាងមុខ ប្រសិនបើមាតាបិតាមិនបានបង់ប្រាក់
- រំពឹងចង់បានការបង់ប្រាក់ មុនការចាប់ផ្តើមឆ្នាំសិក្សា
- បង្ខំ ឬទាមទារមាតាបិតាឲ្យចុះហត្ថលេខាដើម្បីបង់ផ្នែកនៃប្រាក់ EMA របស់ខ្លួនទៅឲ្យសាលារៀន
- ស្នើសុំចំណែកនៃប្រាក់ EMA របស់សាលារៀន ដើម្បីប្រើសំរាប់ការបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្ត (សូមអានទំព័រខាងក្រោយដើម្បីឲ្យបានដឹងពីអត្ថន័យនៃការបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្ត និងប្រាក់បង់ឯទៀត
- ប្រើ ឬសម្តុតប្រើអ្នកប្រមូលប្រាក់បំណុល
- បៀតបៀនយាយី ឬបង្ខិតបង្ខំឲ្យបង់ប្រាក់ (កំណត់ចំណាំ: សាលារៀនអាចផ្ញើរបាយការណ៍បង់ប្រាក់អំពីតម្លៃអប់រំចាំបាច់រហូតដល់ទៅ១ដង ក្នុង១ខែ)។

សន្លឹកព័ត៌មានទី១: ការបង់ប្រាក់របស់មាតាបិតានៅតាមសាលារៀនរដ្ឋ

# INFO SHEET 1: PARENT PAYMENTS IN STATE SCHOOLS (Cambodian)

## ការបង់ប្រាក់សំរាប់មុខរបស់សំខាន់ចាំបាច់ មុខវិជ្ជាតាមការជ្រើសរើស និងការបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្ត

ប្រភេទនៃការបង់ប្រាក់ខុសៗគ្នាអាចមានការច្រឡូកច្រឡំជាខ្លាំង។ មាតាបិតាមានសិទ្ធិសួរសំណួរសាលារៀនអំពីការបង់ប្រាក់ទាំងនេះ។

**ខាងក្រោមនេះគឺជាការគូសបញ្ជាក់ប្រាប់ពីការបង់ប្រាក់ទាំងបីប្រភេទ និងបញ្ហាខ្លះៗដែលកើតមានជាញឹកញយ ព្រមទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើឲ្យធ្វើ។**

### 1. <u>មុខរបស់អប់រំដែលសំខាន់ចាំបាច់</u>

**សាលារៀនអាច*តម្រូវឲ្យបង់ប្រាក់*សំរាប់មុខរបស់អប់រំដែលសំខាន់ចាំបាច់ ដែលមិនរាប់បញ្ចូលនៅក្រោម "ការបង្រៀនអប់រំដោយឥតគិតថ្លៃ" (មើលទំព័រមុន)** ឧទាហរណ៍ សៀវភៅកំណត់ហេតុសាលា ការធ្វើដំណើរទៅបំពេញកីឡានៅសាលារៀន និងការបោះជុំរំខ្លះ។ **សាលារៀនគួររក្សាការបង់ប្រាក់នេះឲ្យមានតិចបំផុត។** សាលារៀនក៏អាចរំពឹងទុកផងដែរឲ្យមាតាបិតាបង់ថ្លៃឯកសណ្ឋានសាលា សៀវភៅរៀន សម្ភារៈរៀនសូត្រ និងប្រដាប់ប្រដារៀនសូត្រដែលសិស្សយកមកផ្ទះក្រោយ ម៉ោងសាលា ឬយកមកប្រើប្រាស់ (ឧទាហរណ៍ គ្រឿងក្អមឆ្នាំង គ្រឿងផ្សំសំរាប់ដាំស្ល)។

| **បញ្ហា:** | **ទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើ:** |
|---|---|
| សាលារៀនអាចទាមទារសំរាប់*ថ្លៃកិច្ចបំរើដែលសំខាន់ចាំបាច់ទាំងឡាយទៅនឹង "ការបង្រៀនអប់រំដោយឥតគិតថ្លៃ"* ក៏ប៉ុន្តែមិនមែនសំរាប់ការបង្រៀនអប់រំរបស់ខ្លួនទេ។ ជួនកាល នេះគឺជាការលំបាកដើម្បីឲ្យបានដឹងពីភាពខុសគ្នា។ សាលារៀន**មិនត្រូវ**គិតថ្លៃពីមាតាបិតាចំពោះ 'ការឧបត្ថម្ភ ធនធាន ការចាត់ចែង និងគ្រឿងបរិក្ខា' ដែលជាផ្នែកនៃការបង្រៀនអប់រំដោយឥតគិតថ្លៃ ដូចជាប័ណ្ណអត្តសញ្ញាណ ការប្រើប្រាស់បណ្ណាល័យ គិលានុបដ្ឋាក ឬការបោះពុម្ពចាំបាច់។ | ➢ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយឧបត្ថម្ភលើការសិក្សា ស្នើសុំឲ្យគេយកចំណែកនៃប្រាក់នេះខ្លះយកទៅបង់លើថ្លៃមុខរបស់សំខាន់ចាំបាច់ទាំងនេះ។<br>➢ សួរសាលារៀនអំពីភាពខុសគ្នារវាង "ការបង្រៀនអប់រំដោយឥតគិតថ្លៃ" ដែលរដ្ឋាភិបាលបង់សំរាប់មុខរបស់ដែលសាលារៀនស្នើសុំឲ្យលោកអ្នកបង់។<br>➢ សូមឲ្យបានច្បាស់ប្រាកដថា លោកអ្នកទទួលច្បាប់ចម្លងនៃគោលការណ៍បង់ថ្លៃសាលារៀន។ |
| **បញ្ហា:**<br>ជួនកាលសាលារៀនបង្ខិតបង្ខំឲ្យបង់ប្រាក់ ដោយបំពានភាពសម្ងាត់ផ្ទាល់ខ្លួន និងប្រកាសឈ្មោះសិស្សជាសាធារណៈ ដោយព្រោះមាតាបិតាខ្លួនមិនបានបង់ប្រាក់។ | **ទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើ:**<br>➢ រំលឹកប្រាប់សាលារៀនថា ការគឺនេះបំពានបទបញ្ជាអំពីរបៀបដែលសាលារៀនត្រូវប្រព្រឹត្តពេលណាគេប្រមូលប្រាក់បង់។<br>➢ ផ្តល់ដំណឹងទៅការិយាល័យអប់រំប្រចាំតំបន់ និងសមាជិកសភា (មើលសន្លឹកព័ត៌មានទី៤) |
| **បញ្ហា:**<br>ជួនកាលសិស្សជ្រើសរើសយកមុខវិជ្ជាដោយព្រោះវាមានតម្លៃថោក ជាជាងជ្រើសរើសយកមុខវិជ្ជាថ្លៃជាងដែលគេចូលចិត្តដើម្បីសិក្សា ឬដែលសមរម្យជាង។ | **ទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើ:**<br>➢ ពន្យល់ប្រាប់នាយកសាលា ហើយស្នើសុំឲ្យគេចុះតម្លៃ។<br>➢ ឲ្យការិយាល័យអប់រំប្រចាំតំបន់ និងសមាជិកសភាដឹងថាតម្លៃនេះប៉ះពាល់ដល់ការជ្រើសរើសមុខវិជ្ជា។ |

### 2. <u>មុខវិជ្ជាតាមការជ្រើសរើសបន្ថែម</u>

មាតាបិតាក៏អាច*ជ្រើសរើស*ផងដែរដើម្បីបង់សំរាប់មុខវិជ្ជាតាមការជ្រើសរើសបន្ថែម ឧទាហរណ៍ មេរៀនភ្លេង សកម្មភាពកម្មវិធីសិក្សាបន្ថែម។

| **បញ្ហា:** | **ទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើ:** |
|---|---|
| នេះមានរួមទាំងមុខរបស់ខ្លះៗដែលសិស្សភាគច្រើនមាន ឬដែលសំខាន់ចាំបាច់សំរាប់កិច្ចការសាលា ដូចជាទូចាក់សោ ទស្សនាវដ្តីសាលា ការបោះពុម្ពកិច្ចការពីខុមព្យូធើរបន្ថែមរបស់សិស្ស ឬសម្ភារៈមុខវិជ្ជាដែលមានគុណភាពខ្ពស់ជាង។ | ➢ និយាយប្រាប់សាលារៀនថាមុខរបស់នោះគួរតែឥតគិតថ្លៃ ពេលណាសំខាន់ចាំបាច់សំរាប់កិច្ចការសាលារបស់កូនលោកអ្នក ឧទាហរណ៍ ការបោះពុម្ពកិច្ចការខុមព្យូធើរនៅសាលារៀនសំរាប់គោលបំណងរៀនសូត្រ ទូចាក់សោសំរាប់ទុកដាក់សៀវភៅ។<br>➢ ស្នើសុំសាលារៀនឲ្យរកវិធីដើម្បីប្រាកដថា កូនរបស់លោកអ្នកត្រូវមិនបានគេបំភ្លេចចោល។ |

### 3. <u>ការបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្ត</u>

សាលារៀនក៏អាច*អញ្ជើញស្នើសុំ*ឲ្យលោកអ្នកបង់ប្រាក់វិភាគទានដោយស្ម័គ្រចិត្តផងដែរ ដែលជាវិភាគទានបង់ទៅឲ្យសាលារៀន ឧទាហរណ៍ សំរាប់អាគារ។

| **បញ្ហា:** | **ទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើ:** |
|---|---|
| ជួនកាលសាលាលរៀនស្នើសុំឲ្យធ្វើវិភាគទានដោយស្ម័គ្រចិត្ត ហាក់ដូចជារំពឹងចង់ឲ្យបង់ប្រាក់ដែរ ជាជាងស្នើសុំឲ្យបង់ប្រាក់។ | ➢ ធ្វើវិភាគទានដែលស្ម័គ្រចិត្តតែប៉ុណ្ណោះ ប្រសិនបើលោកអ្នកប្រាថ្នា ហើយទៅតាមសមត្ថភាពដែលលោកអ្នកអាចនឹងបង់។<br>➢ និយាយប្រាប់សាលារៀនថា គេគួរតែឲ្យបានច្បាស់លាស់ថានេះគឺជាការធ្វើវិភាគទានដោយស្ម័គ្រចិត្ត។<br>➢ ចូលរួម ហើយទៅបំពេញសកម្មភាពសាលា ពេលណាដែលលោកអ្នកអាចធ្វើទៅបាន។ |

### 4. <u>ប្រាក់ជំនួយឧបត្ថម្ភលើការសិក្សា (EMA)</u>

| **បញ្ហា:** | **ទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើ:** |
|---|---|
| ជួនកាលសាលារៀនពុំច្បាស់លាស់ អំពីរបៀបដែលគេចំណាយចំណែកនៃប្រាក់ EMA របស់គ្រួសារ។ | ➢ សួរសាលារៀនអំពីរបៀបដែលគេប្រើប្រាស់ចំណែកនៃប្រាក់ EMA របស់លោកអ្នក។<br>➢ លោកអ្នកអាចណែនាំសាលារៀនឲ្យប្រើប្រាក់នេះ សំរាប់បង់លើមុខរបស់ដែលសំខាន់ចាំបាច់។ |
| **បញ្ហា:**<br>ជួនកាលសាលារៀនប្រើប្រាស់ប្រាក់ EMA សំរាប់ការបង់វិភាគទានដោយស្ម័គ្រចិត្ត។ | **ទាំងកិច្ចការទាំងឡាយដែលបានដាក់ស្នើ:**<br>➢ រំលឹកប្រាប់សាលារៀនថាការនេះមិនបានអនុញ្ញាតឲ្យទេ ហើយស្នើសុំឲ្យរាយប្រាប់ពីការចំណាយនៃអ្វីដែលសាលារៀននឹងចំណាយចេញពីប្រាក់ EMA។<br>➢ ប្រាកដឲ្យបានច្បាស់ថាសាលារៀនបញ្ជូនប្រាក់ EMA ដែលនៅសល់ទៅលោកអ្នកវិញនៅចុងឆ្នាំ។ |

<u>**ក្រសួងអប់រំ និងការិយាល័យអភិវឌ្ឍន៍ខាងបឋមវ័យនៃកុមារភាពតាមទីជនបទ**</u>

**តាមទីជនបទ** Barwon South Western ទូរស័ព្ទ: 5225 1000; Grampians ទូរស័ព្ទ: 5337 8444; Gippsland ទូរស័ព្ទ: 5127 0400; Hume ទូរស័ព្ទ: 5761 2100

**តំបន់ជុំវិញក្រុង** ជុំវិញក្រុងប៉ែកខាងកើត ទូរស័ព្ទ: 8561 2700; ជុំវិញក្រុងប៉ែកខាងត្បូង ទូរស័ព្ទ: 9794 3555; ជុំវិញក្រុងប៉ែកខាងជើង ទូរស័ព្ទ: 9488 9488; ជុំវិញក្រុងប៉ែកខាងលិច ទូរស័ព្ទ: 9291 6500



SPRINGVALE COMMUNITY AID ADVICE BUREAU

Emergency Relief Victoria

Good Shepherd youth & family service